# ខ្ញុំមានតំលៃ
## I am Precious

## យុទ្ធនាការ និង ការប្រកួតដើម្បីតំលៃកម្មករកម្មការិនីកាត់ដេរ

### ប្រវត្តិសង្ខេប

មានកម្មករនិយោជិតប្រមាណជាង ៣៣០ ០០០ នាក់ ធ្វើការងារនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា។ ពួកគេភាគច្រើនគឺជាស្ត្រីក្មេងៗ មានការអប់រំតិចតួចមកពីទីជនបទ ។ ក្រៅពីចំណាយពេលវេលាភាគច្រើនក្នុងមួយថ្ងៃៗរបស់ពួកគេធ្វើការងារនៅក្នុងរោងចក្រ ពួកគេទទួលបានព័ត៌មាននិងដឹងពីឱកាសតិចតួច ដើម្បីពង្រីកមាគ៌ានិងជំនាញសំរាប់ជីវិតរបស់ពួកគេ ។ ជារឿយៗ កម្មករនិយោជិតក្មេងៗទាំងនេះធ្វើចំណាកស្រុកពីតំបន់ជនបទ មកកាន់ក្រុងធំៗ ដោយចាកឆ្ងាយពីស្រុកកំណើត និង គ្រួសាររបស់ពួកគេ ។ តាមរយៈការងារ និង ការផ្ញើប្រាក់របស់ពួកគេ ពួកគេចូលរួមចំណែកយ៉ាងសំខាន់ចំពោះជីវភាពរស់នៅនៃគ្រួសាររបស់ពួកគេ និង ចំពោះការរៀនសូត្ររបស់បងប្អូនពួកគេ។ នៅក្នុងករណីភាគច្រើន ការងារនៅក្នុងរោងចក្រកាត់ដេរគឺជាការងារដំបូងរបស់ពួកគេ ហើយដោយមិនមានការអប់រំពីមុនមកនោះ ពួកគេរៀនជំនាញមូលដ្ឋានដែលចាំបាច់ សំរាប់ការផលិតវាយនភ័ណ្ឌ និង សំលៀកបំពាក់ ។

### គោលដៅ

ដើម្បីលើកកំពស់គុណតំលៃរបស់កម្មករនិយោជិតកាត់ដេរតាមរយៈ ការបង្កើនការយល់ដឹងរបស់សង្គមលើការងារនិងការចូលរួមចំណែករបស់ពួកគេ ការលើកទឹកចិត្តពួកគេអោយដឹងពីតំលៃរបស់ពួកគេក្នុងនាមជាកម្មករនិយោជិតកាត់ដេរ និង ការពង្រីកឱកាសរបស់ពួកគេក្នុងការចូលរួមចំណែកក្នុងឧស្សាហកម្មក៏ដូចជាក្នុងសង្គមទាំងមូល ដោយប្រើប្រាស់សមត្ថភាព និង ជំនាញរបស់ពួកគេ ។

### យុទ្ធនាការ និង ការប្រកួត

ដើម្បីបង្កើតជាព្រឹត្តិការណ៍/ការប្រកួតមួយ សំរាប់កម្មករនិយោជិតកាត់ដេរ ដែលនឹងដើរតួជាមធ្យោបាយក្នុងការផ្សព្វផ្សាយពីសារដែលទាក់ទងនឹងការងារកាត់ដេរដូចជា សុខភាព យេនឌ័រ និង បញ្ហាសង្គមដែលសមស្របដទៃទៀត និង ផ្តល់ឱកាសអោយកម្មករនិយោជិតកាត់ដេរ យល់ពីតំលៃផ្ទាល់ខ្លួន និង ជំនាញសក្តានុពលរបស់ពួកគេ តាមរយៈភាពច្នៃប្រឌិត និង ការបង្កើតថ្មី ។

កម្មវិធីប្រកួតទាំងមូល និង ព្រឹត្តិការណ៍ចុងក្រោយ នឹងដំណើរការទៅក្រោមប្រធានបទចំបងមួយគឺ "**ខ្ញុំមានតំលៃ**" ដែលរួមមានវិញ្ញាសារប្រកួតចំនួនពីរគឺ ការរចនាម៉ូតសំលៀកបំពាក់ និង ការសរសេរបទចំរៀង ។

#### ការរចនាម៉ូតសំលៀកបំពាក់

អ្នកចូលរួម អាចគូសដោយសេរីនូវម៉ូតសំលៀកបំពាក់ស្ត្រីប្រភេទណាក៏បាន សំរាប់ពិធីពិសេសៗ ។ វាអាចជាសំលៀកបំពាក់សំរាប់ពិធីប្រពៃណីជាតិ ឬ ពិធីដទៃផ្សេងទៀត ។

ម៉ូតដែលល្អជាងគេចំនួន ១០ នឹងត្រូវបានជ្រើសរើស ហើយផលិតចេញជាសំលៀកបំពាក់ និង ដាក់បង្ហាញជូននៅក្នុងការប្រកួតចុងក្រោយជាសាធារណៈ ដែលអ្នកជាប់ជ័យលាភីចំនួន ៣ រូប នឹងត្រូវបានប្រកាស ។

#### ការសរសេរបទចំរៀង

អ្នកចូលរួម ត្រូវសរសេរអត្ថបទបទចំរៀង ដែលរៀបរាប់ពីជីវិតរបស់ពួកគេក្នុងនាមជាកម្មករនិយោជិតកាត់ដេរ ពីគ្រួសារ និងសហគមន៍ និង វិស័យកាត់ដេរឬក៏ប្រទេសរបស់ពួកគេ ។

អត្ថបទចំរៀងល្អជាងគេចំនួន ៥ នឹងត្រូវបានជ្រើសរើស និង យកទៅតែងជាមួយនឹងទំនុកភ្លេង ។ ចំរៀងទាំងនេះនឹងត្រូវបានច្រៀងនៅក្នុងការប្រកួតចុងក្រោយជាសាធារណៈ ដែលអ្នកជាប់ជ័យលាភីចំនួន ៣ រូប នឹងត្រូវបានប្រកាស។

#### ព័ត៌មានសំខាន់:

| | |
|---|---|
| ការប្រកួតចាប់ផ្តើមដំណើរការ | ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ |
| ឈប់ទទួលពាក្យចូលរួមការប្រកួត | ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧ |
| ការប្រកួតចុងក្រោយ និង ពិធីបិទ | ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៧ |



### អ្នកដែលអាចចូលរួមការប្រកួត

គ្រប់ស្ត្រី និង បុរសជនជាតិខ្មែរទាំងអស់ដែលធ្វើការងារនៅក្នុងរោងចក្រកាត់ដេរ សុទ្ធតែអាចចូលរួមការប្រកួតនេះបាន ។

### ដើម្បីចូលរួមការប្រកួត

- ការចូលរួមការប្រកួត ធ្វើឡើងដោយមិនគិតថ្លៃ ។
- ការចូលរួមត្រូវធ្វើឡើងជាលក្ខណៈបុគ្គល មិនមែនជាក្រុម ។
- អ្នកចូលរួមអាចផ្ញើម៉ូតសំលៀកបំពាក់ និង អត្ថបទចំរៀងបានតែម្តងប៉ុណ្ណោះ ។
- អ្នកចូលរួមអាចបំពេញពាក្យសុំចូលរួមដែលមានស្រាប់ ឬ ប្រើក្រដាសផ្សេងដាច់ដោយឡែក ដោយមានភ្ជាប់មកជាមួយនូវព័ត៌មានផ្ទាល់ខ្លួន ។

### លក្ខខណ្ឌ

១. លក្ខខណ្ឌសំរាប់ការរចនាម៉ូតសំលៀកបំពាក់
- សំលៀកបំពាក់គួរជាសំលៀកបំពាក់ស្ត្រី សំរាប់ឱកាសពិសេសៗដូចជា ពិធីអាពាហ៍ពិពាហ៍ ពិធីជប់លៀង ឬ ពិធីដទៃទៀត ។
- ខណៈពេលដែលសំលៀកបំពាក់អាចមានលក្ខណៈទំនើប និង ច្នៃប្រឌិត វាគួរឆ្លុះបញ្ចាំងពីប្រពៃណីខ្មែរ ។

២. លក្ខខណ្ឌសំរាប់ការសរសេរបទចំរៀង
- ចំរៀងមិនគួរត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីរិះគន់ ឬ ធ្វើអោយប៉ះពាល់ដល់បុគ្គល ឬ អង្គភាពមួយណាឡើយ ។
- ចំរៀងមិនត្រូវពាក់ព័ន្ធនឹងនយោបាយឡើយ ។
- អ្នកចូលរួមអាចប្រើទំនុកភ្លេងចាស់ ដោយបញ្ជាក់ពីចំណងជើងបទចំរៀងដែលយកមកប្រើ ឬ បង្កើតទំនុកភ្លេងថ្មី ។

### លក្ខណៈវិនិច្ឆ័យនៅក្នុងការជ្រើសរើស

- ពាក់ព័ន្ធនឹងឧស្សាហកម្មកាត់ដេរ
- ភាពដើម មិនចំលងពីគេ
- ភាពច្នៃប្រឌិត
- គុណភាព
- មានសុពលភាពសំរាប់ការធ្វើអាជីវកម្ម

### រង្វាន់ (បញ្ជីរង្វាន់នេះអាចនឹងមានការផ្លាស់ប្តូរ)

- ពានរង្វាន់
- សំលៀកបំពាក់
- ម៉ាស៊ីនដេរ
- កង់
- ទូរទស្សន៍
- វិទ្យុ
- ទូរស័ព្ទដៃ
- កាតទូរស័ព្ទ
- ទឹកប្រាក់

**"ខ្ញុំមានតំលៃ" គឺជាយុទ្ធនាការរួមគ្នាមួយ ក្រោមកិច្ចសហប្រតិបត្តិការរបស់:**
- ក្រសួងកិច្ចការនារី (MoWA)
- គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការពលកម្មអន្តរជាតិ
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)
- មជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ (GIPC)
- ទស្សនាវដ្តីតំលៃនារី
- សហជីពក្នុងប្រទេសកម្ពុជា ដែលចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ

**គណៈវិនិច្ឆ័យដែលចូលរួម មានសមាជិកមកពី:**
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)
- ក្រសួងពាណិជ្ជកម្ម (MoC)
- ក្រសួងកិច្ចការនារី (MoWA)
- ក្រុមហ៊ុនរចនាម៉ូតសំលៀកបំពាក់ក្នុងប្រទេសកម្ពុជា
- អ្នកបញ្ជាទិញសំលៀកបំពាក់អន្តរជាតិ នៅក្នុងប្រទេសកម្ពុជា
- តំណាងកម្មករនិយោជិត
- តំណាងមកពី CAMFEBA ឬ GMAC
- តំណាងមកពីអង្គការសហប្រជាជាតិ និង អង្គការ Bretton Woods